# ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន

## **កម្មវិធីផ្លាស់ប្តូរយុវជន** JENESYS 2016
## (**សេដ្ឋកិច្ច ក្រុមទី៤៖ ផ្នែកជលផល**)

ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦

ឆ្លើយតបតាមការអញ្ជើញរបស់ក្រសួងការបរទេសជប៉ុន យុវជនកម្ពុជាចំនួន២២រូបដែលមានចំណាប់អារម្មណ៍ទៅលើវិស័យជលផលនឹងធ្វើទស្សនកិច្ចទៅកាន់ប្រទេសជប៉ុនពីថ្ងៃទី២៩ ខែវិច្ឆិកា ដល់ថ្ងៃទី៦ ខែធ្នូ ជាមួយក្រុមយុវជនមកពីបណ្តាប្រទេសអាស៊ាន ទីម័រខាងកើត និងប្រទេសឥណ្ឌា ក្រោមកម្មវិធីបណ្តាញផ្លាស់ប្តូរសិស្ស និស្សិតនិងយុវជន រវាងប្រទេសជប៉ុន និងបណ្តាប្រទេសអាស៊ីខាងកើត ដែលហៅកាត់ថា JENESYS 2016។

ក្រុមយុវជននឹងធ្វើទស្សនកិច្ចទៅកាន់ខេត្តវ៉ាកាយ៉ាម៉ាដើម្បីចូលរួមកម្មវិធីផ្លាស់ប្តូរជាមួយស្ថាប័ននានានឹងបណ្តាក្រុមហ៊ុនដែលមានទំនាក់ទំនងទៅនិងវិស័យជលផល។ ពួកគេក៏នឹងមានឱកាសធ្វើទស្សនកិច្ចនៅប្រាសាទវ៉ាកាយ៉ាម៉ាដែលជាប្រាសាទមួយដ៏ល្បីល្បាញនៅប្រទេសជប៉ុន ព្រមទាំងទទួលបាននូវបទពិសោធស្នាក់នៅផ្ទះជាមួយជនជាតិជប៉ុនផងដែរ។ កម្មវិធីលម្អិតនៃដំណើរទស្សនកិច្ចនេះមានភ្ជាប់មកជាមួយ។

កម្មវិធី JENESYS 2016 មានគោលបំណងជម្រុញការយល់ដឹង និងការទុកចិត្តគ្នាទៅវិញទៅមកក្នុងចំណោមប្រជាជនជប៉ុន និងបណ្តាប្រទេសដែលចូលរួម និងដើម្បីកសាងមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការនិងចំណងមិត្តភាពនាពេលអនាគត។ តាមរយៈកម្មវិធីនេះក្រសួងការបរទេសបានអញ្ជើញយុវជនកម្ពុជាចំនួនជាង២០០០នាក់មកហើយតាំងពីឆ្នាំ២០០៧មក។

យើងខ្ញុំសង្ឃឹមថាអ្នកចូលរួម នឹងអាចយល់ដឹងអំពីប្រទេសជប៉ុនកាន់តែជ្រាលជ្រៅថែមទៀត ព្រមទាំងចែករំលែកនូវបទពិសោធរបស់ពួកគេទៅកាន់ប្រជាជនកម្ពុជាបន្ទាប់ពីពួកគេវិលត្រលប់មកវិញ។

---

*Embassy of Japan in the Kingdom of Cambodia*

*Tel: 023 217 161, Fax: 023 216 162*

*Email: info.jpn@pp.mofa.go.jp*

*Official Website: www.kh.emb-japan.go.jp*